**វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**
**មុខវិជ្ជាស្រាវជ្រាវអប់រំ**
**ឆ្នាំទី៣ ឆមាសទី១**

# មេរៀនទី៧៖ ការអានតិពន្ធន៍ស៊ីជម្រៅ

( Reading Literature Critically )

## I.និយមន័យ

ការអាននិពន្ធស៊ីជម្រៅ គឺជាការអានអត្ថបទដោយមានការវិភាគ យល់ដឹង និងគិតពិចារណាដោយជ្រាលជ្រៅ មិនត្រឹមតែទទួលយកព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែសួរខ្លួនឯងថា ព័ត៌មាននេះមានអត្ថន័យយ៉ាងដូចម្តេច មានសារៈសំខាន់អ្វី និងអាចអនុវត្តបានដូចម្តេច។

ការអាននិពន្ធន៍គឺជាការអានឯកសារ ឬអត្ថបទមិនមែនសម្រាប់យល់តែអត្ថន័យផ្ទាល់តែប៉ុណ្ណោះទេ ប៉ុន្តែគឺអានដោយមានការវិភាគ ប្រៀបធៀប សង្ស័យ និងវាយតម្លៃអំពីអត្ថន័យ សារសំខាន់ ទស្សនៈ និងគោលបំណងរបស់អ្នកនិពន្ធ។ ដូចនេះការអាននិពន្ធន៍ស៊ីជម្រៅមានន័យថា៖

- មិនអានតែតាមអក្សរប៉ុណ្ណោះ ប៉ុន្តែអានដោយគិតត្រួតពិនិត្យ។
- វាយតម្លៃប្រភព ឬភាពជឿជាក់បានរបស់អត្ថបទ។
- សួរខ្លួនឯងថា៖ តើអត្ថបទនេះមានអត្ថប្រយោជន៍ដល់ខ្ញុំដែរឬទេ ? តើមានអគតិ ឬទស្សនៈលំអៀងទេ ?
- សម្រេចចិត្តដោយផ្អែកលើភស្តុតាង មិនមែនតាមអារម្មណ៍។

ឧទាហរណ៍

នៅពេលអ្នកអានអត្ថបទស្រាវជ្រាវ អ្នកមិនត្រឹមតែចងចាំទិន្នន័យទេ តែអ្នកក៏ត្រូវសួរទៀតថា៖

- តើអ្នកនិពន្ធប្រើវិធីសាស្ត្រស្រាវជ្រាវត្រឹមត្រូវទេ ?
- តើមានភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រការសន្និដ្ឋានឬទេ ?
- តើមានអ្វីដែលខ្វះត្រូវពិនិត្យបន្ថែមទៀត ?

## II. ហេតុអ្វីចាំបាច់ត្រូវអាននិពន្ធន៍ស៊ីជម្រៅ ?

ការអាននិពន្ធន៍ស៊ីជម្រៅ (Critical Reading) មានសារៈសំខាន់យ៉ាងខ្លាំង ព្រោះវាមិនត្រឹមតែជួយឲ្យយើងយល់អត្ថបទត្រឹមត្រូវទេ ប៉ុន្តែថែមទាំងជួយអភិវឌ្ឍន៍ជំនាញគិត និងវាយតម្លៃ។ ហេតុផលសំខាន់ៗដែលត្រូវអាននិពន្ធន៍ស៊ីជម្រៅ៖

- **បង្កើនការយល់ដឹងជ្រាលជ្រៅ៖** មិនមែនអានតែផ្ទៃលើនៃអត្ថបទទេ តែយល់ពីទស្សនៈ គោលបំណង និងន័យសំខាន់។
- **វាយតម្លៃភាពជឿជាក់បាន៖** ជួយសម្គាល់ថាអត្ថបទ ឬប្រភពណាមួយអាចទុកចិត្តបានឬមានលំអៀង

- **អភិវឌ្ឍន៍ជំនាញគិតវិភាគ៖** ជួយឲ្យអ្នកគិតដោយហេតុផល មិនមែនទទួលយកអ្វីៗដោយគ្មានការសួរសំណួរ។
- **ជួយក្នុងការស្រាវជ្រាវ និងសរសេរ៖** អ្នកអាចយកព័ត៌មានដែលបានវាយតម្លៃរួច មកប្រើសម្រាប់ស្រាវជ្រាវ ឬការសរសេរ ដោយមានភាពត្រឹមត្រូវ និងគាំទ្រដោយភស្តុតាង។
- **ការប្រើប្រាស់ក្នុងជីវិតប្រចាំថ្ងៃ៖** ជួយឲ្យអ្នកអាចសម្រេចចិត្តលើព័ត៌មានក្នុងសង្គម ឬព័ត៌មាននៅលើអ៊ីនធឺណិត ដោយប្រើសេចក្តីយល់ដឹង និងការពិចារណា។

## III.ចំណុចសំខាន់ក្នុងការអាននិពន្ធន៍ស៊ីជម្រៅ

1. ដឹងពីគោលបំណងរបស់អ្នក
    - សូមសួរខ្លួនឯងថា៖ "ខ្ញុំកំពុងស្វែងយល់អ្វីពីអត្ថបទនេះ?"
2. ផ្តោតលើអ្វីដែលអ្នកត្រូវការ
    - ជ្រើសអត្ថបទ ឬផ្នែកដែលពាក់ព័ន្ធ និងមានប្រយោជន៍សម្រាប់គោលបំណងរបស់អ្នក។
3. ជ្រើសយុទ្ធសាស្ត្រអានដែលសមស្របនឹងគោលបំណង និងប្រភេទឯកសារដែលអ្នកកំពុងអាន។
    - Skimming: អានឲ្យលឿន ដើម្បីរកគំនិតទូទៅ។
    - Scanning: ស្វែងរកពាក្យ ឬព័ត៌មានជាក់លាក់។
    - Close Reading: អានយ៉ាងយកចិត្តទុកដាក់ ដើម្បីវិភាគន័យជ្រាលជ្រៅ។
    - Section-Hopping: ជ្រើសរើសអានតែផ្នែកជាក់លាក់មួយចំនួននៃអត្ថបទ ដើម្បីផ្តោតលើ។
4. គិតប្រកបដោយវិចារណញ្ញាណអំពីអ្វីដែលអ្នកអាន

- ការអាននិពន្ធមិនមែនគ្រាន់តែទទួលព័ត៌មានទេ ប៉ុន្តែត្រូវសួរខ្លួនឯង និងវិភាគថា៖
    - តើអ្នកនិពន្ធចង់បង្ហាញអំពីគំនិត ឬគោលបំណងអ្វី?
    - តើអាគុយម៉ង់គាំទ្រដោយភស្តុតាងពិតប្រាកដ ឬទេ?
    - តើមានចំណុចខ្វះខាត ឬអ្វីដែលអ្នកគួរតែសង្ស័យ?
- វាជួយឲ្យអ្នកក្លាយជាអ្នកអានដែលសកម្ម និងមានសមត្ថភាពក្នុងការវាយតម្លៃអត្ថបទ។

## III. គោលបំណងនៃការអាននិពន្ធន៍ស៊ីជម្រៅ

ការអានគឺមិនត្រឹមតែយល់អត្ថន័យនៃពាក្យនៅលើអត្ថបទទេ ប៉ុន្តែធ្វើឲ្យអ្នកចូលរួមក្នុងការពិចារណា និងវិភាគអត្ថបទយ៉ាងម៉ត់ចត់។ វាជួយអ្នកវាយតម្លៃ អានយ៉ាងច្បាស់ និងប្រើព័ត៌មានបានប្រកបដោយប្រសិទ្ធភាព។ គោលបំណងសំខាន់ៗមានដូចជា៖

- **វាយតម្លៃភាពទុកចិត្តនៃប្រភពព័ត៌មាន៖** កំណត់ថាព័ត៌មានមានភាពទុកចិត្ត ត្រឹមត្រូវ និងពាក់ព័ន្ធទេ។
- **យល់អំពីអត្ថន័យជ្រៅ៖** វិភាគអាគុយម៉ង់ ទស្សនៈ មូលហេតុ និងផលប៉ះពាល់ក្នុងអត្ថបទ។
- **អភិវឌ្ឍទស្សនៈផ្ទាល់ខ្លួន៖** ផ្ទុផ្ទងគំនិតក្នុងអត្ថបទជាមួយចំណេះដឹង និងយោបល់ផ្ទាល់ខ្លួន។
- **ធ្វើការសម្រេចចិត្តដោយមានព័ត៌មានគាំទ្រ៖** ប្រើការអានយ៉ាងវិចារណា ដើម្បីណែនាំសកម្មភាព ការដោះស្រាយបញ្ហា ឬស្រាវជ្រាវបន្ត។

- **បង្កើនការយល់ និងការចងចាំ** ៖ការចូលរួមពិចារណា ធ្វើឲ្យអ្នកចងចាំ និងអនុវត្តព័ត៌មានបានល្អប្រសើរជាងមុន។

**ដោយឡែកក្នុងការអាននិពន្ធស៊ីជម្រៅត្រូវផ្តោត៖**

**1.តើវាមានសារៈពាក់ព័ន្ធឬទេ?**

កុំចំណាយពេលអានប្រភព (ឬផ្នែកនៃអត្ថបទ) ដែលមិនពាក់ព័ន្ធ។ អ្វីដែលធ្វើឲ្យអត្ថបទមានសារៈពាក់ព័ន្ធអាចអាស្រ័យទៅលើគោលបំណងអានរបស់អ្នក។

**2.តើវាជាបច្ចុប្បន្នភាពគ្រប់គ្រាន់ឬនៅ?**

ត្រូវប្រាកដថា ព័ត៌មាននៅក្នុងប្រភពដែលអ្នកប្រើមានភាពទាន់សម័យ។ សម្រាប់ប្រធានបទជាច្រើនមានន័យថា អ្នកគួរតែប្រើប្រភពដែលត្រូវបានបោះពុម្ពក្នុងរយៈពេល ១០–១៥ ឆ្នាំចុងក្រោយនេះ។

**3. តើវាជាប្រភពសិក្សាផ្លូវការ(Academic)ឬទេ?**

ប្រភពសិក្សាផ្លូវការត្រូវការកេស្តុតាងនៅក្នុងការសរសេររបស់អ្នក។ ប្រភពទាំងនេះគឺមានភាពទុកចិត្តបានមានលក្ខណៈអោបជិក និងត្រូវបានសរសេរដោយអ្នកដែលមានចំណេះដឹងក្នុងវិស័យរបស់ពួកគេ។

**4. ប្រភពសិក្សាផ្លូវការរួមមាន៖**

- អត្ថបទទស្សនាវដ្តីដែលបានពិនិត្យដោយអ្នកជំនាញ (peer-reviewed journal papers)
- សៀវភៅសិក្សាផ្សេងៗ (textbooks)
- បទបង្ហាញក្នុងសន្និសីទអប់រំផ្សេងៗ (academic conference presentations)
- ប្រភពទិន្នន័យដែលទុកចិត្តបាន (reputable data sources)
- របាយការណ៍ពីរដ្ឋាភិបាល (governmental reports)

## IV. វិធីសាស្ត្រក្នុងការអាននិពន្ធស៊ីជម្រៅ

**ខាងក្រោមគឺជាវិធីសាស្ត្រអានជាក់លាក់មួយចំនួន ដែលតែងតែប្រើក្នុងការអាននិពន្ធស៊ីជម្រៅ៖**

**1.ការអានស្ទីម** (Skimming)

- **គោលបំណង**៖ ដើម្បីទទួលបានទិដ្ឋភាពទូទៅនៃអត្ថបទបានរហ័ស។
- **របៀបអាន**៖ អានចំណងជើង ចំណងជើងរង ប្រយោគដំបូង និងប្រយោគចុងក្រោយនៃកថាខណ្ឌព្រមទាំងពាក្យគន្លឹះ។
- **របៀបប្រើ**៖ មានប្រយោជន៍ពេលសម្រេចចិត្តថាតើអត្ថបទពាក់ព័ន្ធនឹងគោលបំណងរបស់អ្នកឬអត់។

2. **ការអានស្កេន** (Scanning)

- **គោលបំណង**៖ ដើម្បីស្វែងរកព័ត៌មានជាក់លាក់ ដោយមិនចាំបាច់អានអស់ទាំងអត្ថបទ។
- **របៀបអាន**៖ រកពាក្យគន្លឹះ ចំនួន ឈ្មោះ ឬឃ្លាដែលឆ្លើយតបទៅនឹងសំណួររបស់អ្នក។
- **របៀបប្រើ**៖ មានប្រយោជន៍សម្រាប់ការស្រាវជ្រាវ ការត្រួតពិនិត្យព័ត៌មាន ឬស្វែងរកព័ត៌មានលម្អិតឲ្យបានរហ័ស។

3. **ការអានដោយយកចិត្តទុកដាក់** (Close Reading)

- **គោលបំណង៖** អានដោយយកចិត្តទុកដាក់ និងពិចារណាឲ្យបានយ៉ាងជ្រាលជ្រៅ ដើម្បីយល់អត្ថបទពេញលេញ
- **របៀបអាន៖** វិភាគទឡ្ហីករណ៍ ពាក្យសព្ទ រចនាបថប្រយោគ និងភស្តុតាង
- **របៀបប្រើ៖** ចាំបាច់សម្រាប់ការយល់អំពីគំនិតស្មុគស្មាញ ឬពិនិត្យវិភាគអត្ថបទយ៉ាងវិចារណកថា។

4. **ការរំកិលអានតាមផ្នែក** (Section Hopping)

- **គោលបំណង៖** អានឆ្លងកាត់ផ្នែកផ្សេងៗ ដើម្បីស្វែងរកអ្វីដែលពាក់ព័ន្ធបំផុតសម្រាប់គោលបំណងរបស់អ្នក
- **របៀបអាន៖** កុំអានតាមលំដាប់ជួរដេក តែផ្លាស់ទៅកាន់ផ្នែកដែលសំខាន់សម្រាប់អ្នក
- **របៀបប្រើ៖** ជួយសន្សំសំចៃពេលវេលា និងផ្តោតលើផ្នែកដែលមានសារៈសំខាន់បំផុត។

5. **ការវិភាគ** (Analysis)

- **គោលបំណង៖** ដើម្បីបំបែកអត្ថបទជាផ្នែកៗ ដើម្បីយល់ពីរបៀបវាដំណើរការ។
- **របៀបអាន៖** កំណត់អត្តសញ្ញាណគំនិតសំខាន់ៗ ភស្តុតាង ការអះអាង ការសន្មត់ និងរចនាសម្ព័ន្ធ។
- **របៀបប្រើ៖** ជួយឲ្យអ្នកឃើញភាពត្រឹមត្រូវនៃអត្ថបទ និងយល់ពីទំនាក់ទំនងរវាងគំនិត។

6. **ការវាយតម្លៃ** (Evaluation)

- **គោលបំណង៖** ដើម្បីវាយតម្លៃគុណភាព ភាពអាចទុកចិត្តបាន និងសារៈពាក់ព័ន្ធនៃអត្ថបទ។
- **របៀបអាន៖** សួរសំណួរដូចជា តើភស្តុតាងអាចទុកចិត្តបានទេ? តើទឡ្ហីករណ៍សមស្របដែរឬទេ? តើមានភាពលម្អៀងឬអត់?
- **របៀបប្រើ៖** អ្នកទទួលយកតែព័ត៌មានដែលអាចទុកចិត្តបាន និងពាក់ព័ន្ធប៉ុណ្ណោះ។

7. **ការសំយោគគំនិត** (Synthesis)

- **គោលបំណង៖** ដើម្បីបញ្ចូលគំនិតពីប្រភព ឬផ្នែកជាច្រើន រួមបញ្ចូលគ្នា ទៅជាគំនិតយល់ដឹងថ្មី
- **របៀបអាន៖** ប្រៀបធៀប និងរួមបញ្ចូលព័ត៌មាន កំណត់លំនាំ ឬភាពខុសគ្នា ហើយអភិវឌ្ឍទស្សនៈផ្ទាល់ខ្លួន
- **របៀបប្រើ៖** អនុញ្ញាតឲ្យអ្នកបង្កើតយោបល់ ការសន្និដ្ឋាន ឬចក្ខុវិស័យថ្មីៗ ពីអ្វីដែលអ្នកបានអាន។

# បញ្ជីឯកសារយោង


1) Wallace, C., & Wray, A. (2011). *Critical reading and writing for postgraduates*. Sage Publications.
2) Northedge, A. (2005). *The good study guides*. Open University Press.
3) Cottrell, S. (2017). *Critical thinking skills: Effective analysis, argument and reflection*. Macmillan International Higher Education.
4) Wallace, C. (2003). *Critical Reading in Language Education*. Palgrave Macmillan.
5) Norton, L. (2009). *Action Research in Teaching and Learning*. Routledge.
6) Cottrell, S. (2017). *Critical Thinking Skills: Effective Analysis, Argument and Reflection*. Palgrave.
7) Wallace, M., & Wray, A. (2016). *Critical reading and writing for postgraduates* (3rd ed.). Sage.
8) University of Leeds. (2020). *Critical reading techniques*. Skills@Library. https://library.leeds.ac.uk
9) Bailey, S. (2018). *Academic writing: A handbook for international students* (5th ed.). Routledge.
10) Hart, C. (2018). *Doing a literature review: Releasing the research imagination* (2nd ed.). Sage.